# អនុក្រឹត្យ

# ស្ដីពី ការទទួល

# ស្គាល់សមាសភាព

# ការិយាល័យប្រតិបត្តិ

# សភាពាណិជ្ជកម្ម

# ២០០៩

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៣០..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា ១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១២ នៃអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១ ..**

ទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

| | | |
|---|---|---|
| ១- អ្នកឧកញ៉ា | គិត ម៉េង | ប្រធាន |
| ២- ឯកឧត្តមអ្នកឧកញ៉ា | គង់ ទ្រីវ | អនុប្រធាន |
| ៣-ឯកឧត្តមអ្នកឧកញ៉ា | ម៉ែន សារុន | អនុប្រធាន |
| ៤- ឯកឧត្តមឧកញ៉ា | ស៊ីន សុខណា | អនុប្រធាន |
| ៥- ឯកឧត្តមអ្នកឧកញ៉ា | លី យ៉ុងផាត់ | អនុប្រធាន |
| ៦-ឯកឧត្តមឧកញ៉ា | ~~ភុក អាន~~ | អនុប្រធាន |
| ៧- ឯកឧត្តមឧកញ៉ា | ម៉ុង ឫទ្ធី | អនុប្រធាន |
| ៨- ឧកញ៉ា | ហាន់ ឃាង | អនុប្រធាន |
| ៩- ឧកញ៉ា | យ៉ាំ ស៊ុយសាំង | អនុប្រធាន |
| ១០- ឯកឧត្តមឧកញ៉ា | ឡាវ ម៉េងឃីន | អនុប្រធាន |
| ១១- លោកជំទាវឧកញ៉ា | លីម ឈីវហ្គរ | អនុប្រធាន |
| ១២- ឯកឧត្តមឧកញ៉ា | ស៊ីវ ថៃ | អនុប្រធាន |
| ១៣- ឯកឧត្តមឧកញ៉ា | ឡុច សារ៉េត | អនុប្រធាន |
| ១៤-ឧកញ៉ា | ភូ ពុយ | អនុប្រធាន |
| ១៥- លោក | ផេង គង់ | អនុប្រធាន |
| ១៦- ឯកឧត្តមឧកញ៉ា | លីម ហ៊ុយឡេង | អនុប្រធាន |
| ១៧- លោក | លី អ៊ុត នី | អនុប្រធាន |
| ១៨- លោក | អ៊ុំ ឈុន | អនុប្រធាន |
| ១៩- ឧកញ៉ា | អាន ម៉ារឌី | អនុប្រធាន |
| ២០- ឧកញ៉ា | ណាំ ស្រ៊ុន | អនុប្រធាន |
| ២១- ឯកឧត្តមឧកញ៉ា | ឌុយ គី | អនុប្រធាន |
| ២២- លោកជំទាវឧកញ៉ា | កែវ ម៉ាលី | អនុប្រធាន |
| ២៣- ឧកញ៉ា | យ៉ែម កុសល | អនុប្រធាន |
| ២៤- លោក | ម៉ុន ឌុន | អនុប្រធាន |
| ២៥- ឯកឧត្តមឧកញ៉ា | គិត ឆៀង | ហេរញ្ញិក |
| ២៦- ឧកញ៉ា | ទី ពិសិដ្ឋ | លេខាធិការ |

**មាត្រា ២ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ